# THE SCHOOL DISTRICT OF PHILADELPHIA

**“Please complete the English version of the document, the target language version will be automatically completed”**

**School ______________________**

**Address ________________________________**

**Philadelphia, PA ____________**

**Telephone _______________________________**

**Student _______________________ I.D.__________**

**Parent ________________________**

Date________________

Dear Parents/Guardians:

Enclosed, please find your child’s report card for the _____ **Marking Period** for the ___________ **Academic year**. We are asking that you review the report card very carefully.

**Teachers of students who are “in danger of failing” will contact parents within the next few days to schedule either a phone conference or a face-to-face conference at a time that is conducive to both parents and teachers.**

All parents are encouraged to contact their child’s teacher to discuss their child’s progress to date.

Thank you for being a partner in your child’s education.

Sincerely,

_______________________

Principal

# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា
# THE SCHOOL DISTRICT OF PHILADELPHIA

**សាលា/*School*** ________________________

**អាស័យដ្ឋាន/*Address*** ______________________________

**Philadelphia, PA** ___________

**ទូរស័ព្ទ/*Telephone*** ____________________________

**សិស្ស/*Student*** _____________________ **អត្តលេខ/I.D.**__________

**មាតាបិតា/*Parent*** ______________________

ថ្ងៃខែ/*Date* _______________

ជូនចំពោះ មាតាបិតា/អាណាព្យាបាលៈ

សូមមើលរបាយការណ៍ពិន្ទុរបស់កូនលោកអ្នកដែលភ្ជាប់មកជាមួយនេះ សម្រាប់ត្រីមាសទី____ ***Marking Period*** **ឆ្នាំសិក្សា/*Academic Year*** __________។ យើងខ្ញុំសុំឲ្យលោកអ្នកពិនិត្យមើលរបាយការពិន្ទុនេះដោយយកចិត្តទុកដាក់។

**គ្រូរបស់សិស្សដែល «ស្ថិតនៅក្នុងស្ថានភាពរៀនធ្លាក់» នឹងទាក់ទងទៅមាតាបិតាក្នុងកំឡុងពេលពីរបីថ្ងៃខាងមុខនេះ ដើម្បីណាត់ជួបប្រជុំ តាមទូរស័ព្ទ ឬទល់មុខគ្នា នៅពេលណាមួយដែលមាតាបិតា និង គ្រូ អាចជួបគ្នាបាន។**

សុំឲ្យមាតាបិតាទាំងអស់ទាក់ទងទៅគ្រូរបស់កូន ដើម្បីពិភាក្សាអំពីការរីកចម្រើនរបស់កូនមកទល់សព្វថ្ងៃនេះ។

សូមអរគុណចំពោះការសហការក្នុងការអប់រំកូនរបស់លោកអ្នក។

ដោយសេចក្តីស្មោះស្ម័គ្រ

_________________________

នាយកសាលា/*Principal*

# មូលវិចារអំពីរបាយការណ៍ពិន្ទុសម្រាប់ ថ្នាក់ទី៤ ដល់ ថ្នាក់ទី៨

**Grades 4-8 Report Card Comments**

(ចំណុចដែលមានគំនូស (✓) រៀបរាប់អំពីកូនរបស់លោកអ្នក)

Teacher: Please put a checkmark ✓ in the middle column of the items that apply to the student

សាលា/*School*________________________

គ្រូ/*Teacher*________________________

មាតាបិតា/*Parent*________________________

សិស្ស/*Student*________________________ អត្តលេខ/I.D#.________________

| **Comments** | | **មូលវិចារ** |
|---|---|---|
| **Character Building and Behavior Pattern (positive)** | | **លំនាំនៃ លក្ខណៈសម្បត្តិ និង អាកប្បកិរិយា (វិជ្ជមាន)** |
| Is conscientious and works hard | | យកចិត្តទុកដាក់ និងខំប្រឹងសិក្សា |
| Follows directions | | ធ្វើតាមការណែនាំ |
| Works cooperatively with others | | សហការជាមួយសិស្សដទៃទៀត |
| Uses time appropriately and is organized | | ចេះប្រើពេលវេលា និងចេះរៀបចំ បានល្អ |
| Demonstrates consistent effort | | បង្ហាញឲ្យឃើញនូវការខិតខំជាបន្ត |
| Follows school and classroom rules | | ធ្វើតាមវិន័យរបស់ សាលា និងថ្នាក់រៀន |
| Accepts responsibility | | មានការទទួលខុសត្រូវ |
| Respects the rights and feelings of others | | គោរព សិទ្ធិ និងអារម្មណ៍ របស់អ្នកដទៃ |
| Sets a positive example for the rest of the class | | ធ្វើជាគំរូល្អដល់សិស្សរួមថ្នាក់ទាំងអស់ |
| Is polite and courteous | | ចេះគួរសម ហើយសុភាពរាបសារ |
| Manages own behavior | | ចេះរៀបចំអាកប្បកិរិយាបានល្អ |
| Works well with partner and/or learning group | | ធ្វើអ្វីៗជាមួយដៃគូរ និង/ឬ ជាមួយក្រុមសិក្សា បានល្អ |
| Handles conflict appropriately | | ចេះដោះស្រាយទំនាស់បានល្អ |
| Demonstrates leadership skills | | មានលក្ខណៈជាអ្នកដឹកនាំ |
| Helpful in resolving conflict | | ពូកែដោះស្រាយទំនាស់ |
| Honors diversity of fellow students | | គោរពភាពខុសគ្នារបស់សិស្សានុសិស្សដទៃ |

| | | |
|---|---|---|
| Helpful to classmates and others | | ចេះជួយសិស្សរួមថ្នាក់ និងអ្នកដទៃទៀត |
| Makes friends readily | | ងាយស្រួលក្នុងការរាប់អានមិត្តភ័ក្ត |
| **Character Building and behavior pattern (Negative)** | | **លំនាំនៃ លក្ខណ:សម្បត្តិ និង អាកប្បកិរិយា (អវិជ្ជមាន)** |
| Does not get along with peers | | មិនត្រូវគ្នាជាមួយសិស្សដទៃ |
| Disrespectful of others | | មិនគោរពអ្នកដទៃ |
| Needs improvement in attitude | | ត្រូវកែលម្អអាកប្បកិរិយា |
| Does not wear school uniform | | មិនស្លៀកពាក់ឯកសណ្ឋានរបស់សាលា |
| Handles conflict inappropriately | | មិនចេះដោះស្រាយទំនាស់ |
| Must learn to control his/her behavior | | ត្រូវរៀនគ្រប់គ្រងអាកប្បកិរិយារបស់ខ្លួន |
| Excessive lateness | | មករៀនយឺតពេលច្រើនដង |
| Excessive absences | | អវត្តមានច្រើនដង |
| Inattentive-89 | | មិនយកចិត្តទុកដាក់ |
| Does not work well in cooperative groups | | មិនចេះសហការនៅពេលសិក្សាជាក្រុម |
| Wastes time, not on task | | ចំណាយពេលវេលឥតប្រយោជន៍ ធ្វើកិច្ចការមិនទាន់ពេល |
| Disrupts instruction | | រំខានដល់ការបង្ហាត់បង្រៀន |
| **Academic Performance (Positive)** | | **លទ្ធផលនៃការសិក្សា (វិជ្ជមាន)** |
| Excellent in effort, attention and preparation | | ខំប្រឹងប្រែង យកចិត្តទុកដាក់ និង ប្រុងប្រៀប បានល្អ |
| Produces quality work | | ធ្វើកិច្ចការបានល្អ |
| Thinks things through and provides reasons for opinions | | គិតគូរច្បាស់លាស់ និងផ្តល់គំនិតយោបល់ ដោយសមហេតុផល |
| Imaginative, has lots of ideas, thinks of ways to solve problems | | មានប្រឌិតញាណ មានគំនិតច្រើន ចេះគិតពីមធ្យោបាយផ្សេងៗដើម្បីដោះស្រាយបញ្ហា |
| Participates thoughtfully in discussions | | ចូលរួមក្នុងការពិភាក្សា ដោយមានការគិតគូរច្បាស់លាស់ |
| Practices mindful learning and welcomes new ideas | | បើកចិត្តឲ្យទូលាយក្នុងការសិក្សា ហើយស្វាគមន៍គំនិតថ្មីៗ |
| **Academic Performance(Negative)** | | **លទ្ធផលនៃការសិក្សា (អវិជ្ជមាន)** |
| Assignments are sometimes incomplete | | ជួនកាលធ្វើកិច្ចការដែលគ្រូដាក់ឲ្យធ្វើ មិនហើយ |
| Low test grades | | ប្រឡងបានពិន្ទុទាប |
| Difficulty following written directions | | ពិបាកធ្វើតាមការណែនាំ ដែលគេសរសេរប្រាប់ |
| Difficulty following oral directions | | ពិបាកធ្វើតាមការណែនាំ ដែលគេនិយាយប្រាប់ |

| | | |
|---|---|---|
| Failure to make up work | ☐ | មិនធ្វើសងកិច្ចការដែលមិនបានធ្វើពីមុន |
| Assignments missing | ☐ | បាត់បង់កិច្ចការដែលគ្រូដាក់ឲ្យធ្វើ |
| Homework missing | ☐ | បាត់បង់កិច្ចការដែលគ្រូដាក់ឲ្យធ្វើនៅផ្ទះ |
| Has trouble with reading comprehension | ☐ | មានការលំបាកក្នុងការស្វែងយល់អត្ថបទដែលបានអាន |
| Fails to bring supplies to school | ☐ | មិនយកសម្ភារៈសិក្សាមកសាលា |
| Has trouble reading unfamiliar words | ☐ | មិនចេះអានពាក្យថ្មីៗ ដែលមិនធ្លាប់ស្គាល់ |
| Needs improvement in math skills | ☐ | ត្រូវការបង្កើនចំណេះដឹងផ្នែកគណិតវិទ្យា |
| Lacks basic skills | ☐ | ខ្វះខាតចំណេះដឹងមូលដ្ឋាន |
| Assignments are incomplete or missing | ☐ | ធ្វើកិច្ចការដែលគ្រូដាក់ឲ្យធ្វើ  មិនហើយ ឬ មិនប្រគល់ឲ្យគ្រូ |
| **Progress** | | **ការរីកចម្រើន** |
| Commendable progress | ☐ | មានការរីកចម្រើនដែលគួរឲ្យសរសើរ |
| Shows improvement in work | ☐ | បង្ហាញឲ្យឃើញនូវការរីកចម្រើនក្នុងការធ្វើកិច្ចការ |
| **ESOL or Special Education related issues** | | **បញ្ហាដែលទាក់ទងនឹងកម្មវិធី ESOL ឬ ការអប់រំពិសេស** |
| Grade is based on adaptations/accommodations in accordance with IEP | ☐ | ពិន្ទុយោងទៅតាម លំនាំ/ការរៀបចំ ដែលស្របតាម IEP |
| Supplementary instruction/support from Resource Room teacher | ☐ | ការបង្ហាត់បង្រៀន/ជំនួយ បន្ថែម ពីគ្រូប្រចាំថ្នាក់ |
| Grade is based on an instructionally appropriate level | ☐ | ពិន្ទុយោងទៅតាមការបង្ហាត់បង្រៀនដែលត្រូវតាមកម្រិតថ្នាក់ |
| No grade due to late admission | ☐ | គ្មានពិន្ទុ ដោយសារចុះឈ្មោះចូលរៀនយឺតពេល |
| No grade due to beginner ESOL status | ☐ | គ្មានពិន្ទុ ដោយសារទើបនឹងចាប់ផ្តើមកម្រិតថ្នាក់ ESOL |
| No grade due to medical reasons | ☐ | គ្មានពិន្ទុ ដោយសារមានជម្ងឺ |
| Subject is taught in both languages of the bilingual program | ☐ | មុខវិជ្ជាបានបង្រៀនជាពីរភាសា តាមកម្មវិធីពីរភាសា |
| **Intervention** | | **ការធ្វើអន្តរាគមន៍** |
| Parent conference requested | ☐ | សុំជួបប្រជុំជាមួយមាតាបិតា |

**យោបល់បន្ថែម/Additional Note**

មិនដឹងថាសាលាបិទ បើសិនជាអាកាសធាតុមិនល្អ?/ Do not know if schools are closed when weather turns bad?

ស្វែងរកថ្នាក់រៀនភាសាអង់គ្លេសសម្រាប់មនុស្សពេញវ័យ ដែលនៅជិតកន្លែងលោកអ្នករស់នៅ?/ Looking for adult English class near where you live?

ត្រូវការអ្នកដែលចេះភាសារបស់លោកអ្នក ឲ្យជួយលោកអ្នកដោះស្រាយបញ្ហានៃការសិក្សារបស់កូនលោកអ្នក?/ Need someone who understands your language to help you in dealing with issues of your child's education?

សូមមើល វ៉ិបសៃ/ Please visit៖ www.philasd.org/language/khmer ដែល ***សេចក្តីត្រូវការរបស់លោកអ្នក ជាកិច្ចការសំខាន់របស់យើងខ្ញុំ!***

**ព្រឹត្តិបត្រពន្ទុ របស់** ( REPORT OF )

**ឈ្មោះសិស្ស** (STUDENT NAME) -

______________________________

**អត្តលេខ** ( STUDENT ID )______________

**ព្រឹត្តិបត្រពន្ទុ ថ្នាក់ទី៤-៨** ( GRADES 4 - 8 )
**បំណាច់ឆ្នាំ ខែមិថុនា ២០____**
**CYCLE ____**

***លេខសាលា***/*SCHOOL #* ______ ***ឈ្មោះសាលា***/ *SCHOOL NAME*______________

**នាយក**/ *PRINCIPAL* ______________________________

**ឈ្មោះគ្រូ**/*TEACHER* ______________________________

**បន្ទប់លេខ** _____ **ថ្នាក់ទី** _____

| **មុខវិទ្យា** | **ត្រីមាស** ទី១ ពិន្ទុ | ទី១ ការខំប្រឹងប្រែង | ទី១ អាកប្បកិរិយា | ទី២ ពិន្ទុ | ទី២ ការខំប្រឹងប្រែង | ទី២ អាកប្បកិរិយា | ទី៣ ពិន្ទុ | ទី៣ ការខំប្រឹងប្រែង | ទី៣ អាកប្បកិរិយា | ទី៤ ពិន្ទុ | ទី៤ ការខំប្រឹងប្រែង | ទី៤ អាកប្បកិរិយា | ពិន្ទុចុងក្រោយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ការអាន** | | | | | | | | | | | | | |
| **ការសរសេរ** ( សម្រាប់ត្រីមាសនីមួយៗ យ៉ាងតិចបំផុតមានគំរូបួន ) | | | | | | | | | | | | | |
| **គណិតសាស្ត្រ** | | | | | | | | | | | | | |
| **វិទ្យាសាស្ត្រ** | | | | | | | | | | | | | |
| **សង្គមសាស្ត្រ** | | | | | | | | | | | | | |
| **កាយវប្បកម្ម** | | | | | | | | | | | | | |
| **ការអប់រំសុខភាព** | | | | | | | | | | | | | |
| **ដន្ត្រី** | | | | | | | | | | | | | |
| **សិល្បៈគំនូរ** | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |

## យោបល់

| **មុខវិទ្យា** | **យោបល់** |
|---|---|
| | |
| | |

កំណាត់ទិសដៅនៃកម្មវិធីសម្រាប់ការអាន ប្រចាំត្រីមាស *(សូមមើលការពន្យល់នៅទំព័រម្ខាងទៀត)* ______________________________

| | | | | | |
|---|---|---|---|---|---|
| កម្រិតនៃការអានតាមការបង្ហាត់ របស់កូនលោកអ្នក ប្រចាំត្រីមាស | | | | | |
| កិច្ចការ- រៀនតាមការអនុវត្តន៍ផ្ទាល់/មុខវិទ្យាចម្រុះ (នៅចុងបញ្ចប់ថ្នាក់ទី៨) | | | | | |
| **សតវត្សទី២១ / ការអភិវឌ្ឍន៍ផ្នែកអត្តចរិត** | | | | | |
| បង្ហាញនូវការគោរព និងមេត្តាធម៌ ដល់អ្នកដ៏ទៃ | | | | | |
| ឈ្លាសវៃក្នុងការប្រើពេលវេលា | | | | | |
| ចេះសហការជាមួយអ្នកឯទៀតៗ | | | | | |
| ប្រើការលំបាកជាឱកាសរៀនសូត្រ | | | | | |
| | | | | | |
| | | | | | |
| | | | | | |

## ការគាំទ្រការសិក្សា

| **វត្តមានអវត្តមាន** | **ត្រីមាស** ទី១ | ទី២ | ទី៣ | ទី៤ | ចុងក្រោយ |
|---|---|---|---|---|---|
| ចំនួនថ្ងៃវត្តមាន | | | | | |
| ចំនួនថ្ងៃអវត្តមាន | | | | | |
| ឈប់គ្មានមូលហេតុ | | | | | |
| ម៉ោងមករៀនយឺតពេលវេលា | | | | | |

**តើលោកអ្នកដឹងទេថា**...លោកអ្នកអាចមើលព័ត៌មានពីកូនរបស់លោកអ្នកដែលផ្ទុកក្នុងកុំព្យូទ័រ ពីការរីកចម្រើន ពីពិន្ទុ ពីវត្តមានអវត្តមាន ពិន្ទុនៃការប្រឡង benchmark ពិន្ទុនៃការប្រឡងតាមគំរូទូទៅ (standardized test) និងព័ត៌មានជាច្រើនទៀតក្នុងអ៊ីនធ័រនែត តាមរយៈ **familynet**? ដើម្បីជ្រាបពីព័ត៌មាននេះ សូមមើលតាមវិបសៃរបស់យើងខ្ញុំ៖ **http://www.philasd.org** ហើយចុចត្រង់ពាក្យ login ។

**ពិន្ទុ**
A - 90 - 100
B - 80 - 89
C - 70 - 79
D - 65 - 69
F - 0 – 64
NG – គ្មានពិន្ទុ

**លទ្ធផលនៃ**
**ការធ្វើកិច្ចការ ការខំប្រឹងប្រែង និងអាកប្បកិរិយា**
១ - ល្អណាស់
២ - ពេញចិត្ត
៣ - ត្រូវការកែលម្អ

**គំនូសសម្គាល់សម្រាប់កិច្ចការ**
N - មិនទាន់ចាប់ផ្តើមនៅឡើយ
I - កំពុងមានដំណើរទៅមុខ
C - ចប់រួចរាល់

**ពត៌មានបន្ថែមមាននៅទំព័រម្ខាងទៀត** **សូមមើលក្នុងសៀវភៅណែនាំពីការរៀនសូត្រសម្រាប់មាតាបិតា**

**ក្រសួងអប់រំ**
**នៃ**
**ទីក្រុងហ្វីឡាដែលហ្វ្យ៉**

ជូនចំពោះមាតាបិតា/អាណាព្យាបាល

គោលបំណងរបស់យើងខ្ញុំគឺ ផ្តល់ឲ្យលោកអ្នកនូវរបាយការណ៍ពីពិន្ទុសម្រាប់ថ្នាក់ទី៤-៨ ដែលអាចឲ្យលោកអ្នក ជ្រាបយ៉ាងច្បាស់លាស់ មានលទ្ធភាព និងអាចចូលរួមក្នុងការអប់រំកូនរបស់លោកអ្នក។ សូមពិនិត្យមើលពិន្ទុនិងយោបល់របស់គ្រូបង្រៀនសាឡើងវិញ ជាមួយកូនលោកអ្នក ហើយបើមានសំណួរអ្វី សូមទាក់ទងមកសាលា ឬគ្រូបង្រៀនរបស់កូនលោកអ្នក។

នៅក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ យើងបានទទួលស្គាល់ថា មាតាបិតា/អាណាព្យាបាល ជាដៃគូរបស់យើងខ្ញុំ ហើយនៅតែជាផ្នែកមួយ នៃការសហការដើម្បីធ្វើឲ្យកូនរបស់ យើង ទទួលការអប់រំដ៏ល្អជាទីបំផុត។ ដើម្បីធ្វើឲ្យមានទំនាក់ទំនងរវាង មាតាបិតា និងសាលា យើងខ្ញុំបានផ្តល់ជូននូវការណែនាំពីវិធីគាំទ្រនៅផ្ទះ ដែលជាជំនួយ ជួយកូនរបស់យើងឲ្យ ពង្រីកការសិក្សារបស់ពួកគេ ពីសាលាទៅដល់ផ្ទះ។ ការធ្វើដូច្នេះនឹងបង្ហាញឲ្យកូនរបស់ យើង ដឹងថា ពួកគេមានការរៀនសូត្រដ៏យូរអង្វែងនៅក្នុងជីវិត។

យើងខ្ញុំស្វាគមន៍លោកអ្នកនៅសាលារបស់យើង ហើយរង់ចាំជួបជាមួយលោកអ្នក ដើម្បីពិភាក្សាពីការរីកចម្រើនរបស់កូនលោកអ្នក។
ដោយសេចក្តីគោរពរាប់អាន

William R. Hite, Jr., Ed.D. អគ្គនាយក

# ការណែនាំពីវិធីគាំទ្រនៅផ្ទះ សម្រាប់ថ្នាក់ទី៤-៨

## កម្រិតនៃការអានតាមកម្មវិធីបង្រៀន ថ្នាក់ទី៤-៨

កម្រិតនៃការអានតាមកម្មវិធីបង្រៀន បង្ហាញថាតើកូនរបស់លោកអ្នក អានបានកម្រិតណា។ កម្រិតអាន 4.5 មានន័យថា កូនរបស់លោកអ្នកកំពុងអានតាមកម្រិតថ្នាក់ទី៤ នៅពាក់កណ្តាលឆ្នាំ។ កម្រិតអាន 8.0 មានន័យថា កូនរបស់លោកអ្នក កំពុងអានតាមកម្រិតថ្នាក់ទី៨ នៅដើមឆ្នាំ។

**1.0-1.5** អ្នកអានពឹងផ្អែកលើជំនួយពីគ្រូបង្រៀនដើម្បីយល់ពីមូលដ្ឋានរបស់សៀវភៅ និងពាក្យ។ ពួកគេអាចអានពាក្យដែលគេប្រើញឹកញាប់ ដូចជា the, a, at …។ សិស្សានុសិស្សពឹងផ្អែកលើរូបភាពដើម្បី ជួយពួកគេឲ្យយល់អត្ថន័យរបស់ឃ្លា។ អក្សរធំៗ ប្រើឃ្លាខ្លីៗលើទំព័រ គឺជាការចាំបាច់ សម្រាប់ការយល់ដឹង។

**2.0-2.5** អ្នកអានចាប់ផ្តើមរៀនពីវិធីរិះគិតដល់ពាក្យផ្សេងៗ ហើយអាចយល់ឃ្លាប្រយោគកាន់តែច្រើនឡើង។ សិស្សានុសិស្សនៅតែពឹងផ្អែកលើជំនួយពីគ្រូបង្រៀនដើម្បីយល់ពីឃ្លាប្រយោគ។ សិស្សានុសិស្សយល់ថា ការអានបំពេញនូវគោលបំណងជាច្រើន ដូចជា ការកំសាន្ត ផ្តល់ព័ត៌មាន ឬក៏បញ្ចុះបញ្ចូល។ សិស្សអាចដឹងពីលក្ខណៈខុសគ្នារវាង រឿងពិត និង រឿងប្រឌិត និងមិនសូវពឹងផ្អែកលើរូបភាព ហើយអាចអានឃ្លាបានកាន់តែច្រើន នៅក្នុងទំព័រ។

**3.0-3.5** អ្នកអានមិនពឹងផ្អែកខ្លាំងលើការគិតពីអត្ថន័យរបស់ពាក្យ។ សិស្សានុសិស្សចាប់ផ្តើមយល់អត្ថបទដោយខ្លួនឯង។ សិស្សានុសិស្សក៏អាចស្គាល់នូវប្រភេទខុសៗគ្នានៃអត្ថបទ ហើយអាចអានអត្ថបទដែលមានឃ្លាប្រយោគវែងៗ មានពាក្យច្រើនក្នុង ំព័រ ហើយមានពាក្យដែលមានអត្ថន័យជ្រៅៗ។

**សេចក្តីសង្ឃឹមគឺ ចង់ឲ្យសិស្សានុសិស្សអានបានតាមកម្រិតថ្នាក់ ឬលើកម្រិតថ្នាក់។**

**4.0-4.5** អ្នកអានអាចយល់ពីអត្ថបទប្លែកៗពីគ្នា។ ការអានភាគច្រើនគឺ អានដោយស្ងៀមស្ងាត់។ អ្នកអានភាគច្រើនយល់ពីគំនិតដែលខុសប្លែកៗពីគ្នា ហើយយកការប៉ិនប្រសប់ក្នុងការស្វែងយល់ពីអត្ថន័យរបស់ពាក្យមកប្រើ ដើម្បីយល់ពាក្យ និងឃ្លា ដែលពិបាកៗ។

**5.□-5.5** អ្នកអានយល់ពីអត្ថបទខុសៗគ្នា។ អត្ថបទកាន់តែវែង ដែលតម្រូវឲ្យមានការសញ្ជឹងគិតដើម្បីបញ្ចេញយោបល់ ចំពោះរឿងប្រឌិត ក៏ដូចជារឿងពិត។

**6□0-6.5** អ្នកអានយល់ពីអត្ថបទទាំងអស់។ អត្ថបទវែងៗ ស្មុគស្មាញ ដែលមានប្រយោគ វគ្គ និងពាក្យដែលមានព្យាង្គច្រើន (ដូចជាពាក្យ bankruptcy, uplifting ។ល។) ដែលគេចង់ឲ្យអ្នកអានយល់ និងអាចឆ្លើយតបបាន។

**7.0□7.5** អ្នកអានយល់អត្ថបទទាំងអស់ ដែលមាននិយាយពីអត្ថន័យសម្រាប់មនុស្សពេញវ័យ ដូចជាការធ្វើបាប ជីវិតក្រីក្រ និង ពីសង្គ្រាម។ អត្ថបទកាន់តែវែងៗ ហើយស្មុគស្មាញ រួមទាំងវគ្គ និងប្រយោគ ដែលមានការប្រែប្រួល សម្រាប់អ្នកអានស្វែងយល់ ហើយគេសង្ឃឹមថា អ្នកអានអាចឆ្លើយតបបាន។

**8.0-8.5** អ្នកអានយល់ពីអត្ថបទផ្សេងៗជាច្រើន។ ភាគច្រើន អានដោយស្ងៀមស្ងាត់។ ចាប់ផ្តើមការអានដោយគ្មានកំហុស។ សាច់រឿង និងតួអង្គ មានលក្ខណៈសម្បត្តិ ខុសៗគ្នាជាច្រើន ហើយគេអាចយល់តាមកម្រិតខុសៗគ្នា។

**9.0-10.0** (**អ្នកចេះអានយ៉ាងស្ទាត់ជំនាញ**) អ្នកចេះអានយ៉ាងស្ទាត់ជំនាញ បានរៀនអានដោយជោគជ័យ។ ឥឡូវនេះ គោលបំណងរបស់ពួកគេគឺអានឲ្យយល់ ក្នុងបំណងស្វែងយល់អត្ថន័យពីអ្វីៗដែលគេអាន។ ពួកគេអានដោយមានមនោសញ្ចេតនា និងតាមលំនាំប្រើវណ្ណយុត្ត ដើម្បីអានឲ្យបានស្រួល និងច្បាស់ៗ។ ការបង្កើនការអានដោយឯករាជ្យ នឹងបង្កើនការប៉ិនប្រសប់ក្នុងការយល់ដឹងរបស់ពួកគេ ដើម្បីអានអត្ថបទដែលពិបាកៗ។

### ការអាន

- បង្កើតបណ្ណាល័យនៅផ្ទះ ដែលមានសៀវភៅអានខុសៗគ្នា។
- សួរសំណួរអំពីសាច់រឿងទាំងនោះ៖ "តើមានអ្វីកើតឡើងពីដំបូង នៅពាក់កណ្តាល និងនៅចុងបញ្ចប់ នៃសាច់រឿង។"
- ជ្រើសរើសសៀវភៅ ទស្សនាវដ្តី និងអត្ថបទ សម្រាប់អាន។
- អានកាសែត ហើយពិភាក្សាពីព្រឹត្តិការណ៍ថ្មីៗ។ ចូរឲ្យកូនឃើញនៅពេលលោកអ្នក អានកំសាន្ត និងអានដើម្បីស្វែងយល់ព័ត៌មាន (កាសែត កំណាព្យ)។
- ធ្វើឲ្យក្លាយទៅជាអ្នក ទៅបណ្ណាល័យសាធារណៈញឹកញាប់។
- ពិភាក្សាពីការផ្សាយពាណិជ្ជកម្ម ដែលអ្នកបានឃើញ ក្នុងទូរទស្សន៍ និងនៅតាមតំបន់ជាមួយកូនរបស់លោកអ្នក។ (តើគេផ្សាយអំពីអ្វី?)

### គណិតសាស្ត្រ

- រកមើលសកម្មភាពពិតៗដែលតម្រូវឲ្យកូនលោកអ្នកប្រើជំនាញ ខាងគណិតសាស្ត្រ ដូចជា វាល់គ្រឿងធ្វើម្ហូប។
- រៀបចំគម្រោងការណ៍ធ្វើដំណើរតាមការជិះ SEPTA ក្នុងដី រទេះភ្លើង និងរថយន្តក្រុង ដោយប្រើតារាងពេលវេលា។
- លើកទឹកចិត្តកូនឲ្យប្រើគណិតសាស្ត្រតាមការប្រើខួរក្បាលនៅពេលទៅទិញឥវ៉ាន់។
- ប្រើព័ត៌មានកីឡា ដើម្បីសម្រេចលើការស្រង់ស្ថិតិ ដូចជារកមើលមធ្យមភាគនៃការវាយបាល់ដែលអ្នកលេង baseball បានវាយបាល់។
- នាំកូនលោកអ្នកឲ្យចូលរួមក្នុងការរកមើលផ្លូវនៅលើផែនទី និងផ្តល់ទិសដៅទៅកាន់កន្លែងដែលត្រូវទៅ ដូចជា ខាងជើង ខាងត្បូង ខាងកើត ខាងលិច ឬបន្ទាត់សម្រាប់វាស់ចម្ងាយ។
- សម្គាល់ និងបែងចែកនូវទ្រង់ទ្រាយរេខាគណិតនៅក្នុងផ្ទះ ឬក្នុងតំបន់របស់លោកអ្នក។
- នាំឲ្យកូនចូលរួមក្នុងការជួសជុល និងកែលម្អផ្ទះ ដូចជា វាស់បន្ទប់ដើម្បីក្រាលព្រំ។ ហើយឲ្យក្មេងគិតពីតម្លៃ ផងដែរ។

### វិទ្យាសាស្ត្រ

- លើកទឹកចិត្តក្មេងដើម្បីឲ្យមានការចង់ដឹងចង់ឃើញ និងសួរសំណួរ។ សមាជិកក្រុមគ្រួសារអាចចូលរួមក្នុងការគិតរកអ្វីមួយ ដោយប្រាប់ក្មេងថា “ខ្ញុំមិនដឹងដែរ ប៉ុន្តែយើងអាចរកចម្លើយនេះទាំងអស់គ្នា”។
- សួរកូនរបស់លោកអ្នកថាតើពួកគេរៀនអ្វីនៅសាលា។ ពិភាក្សា ថាតើវិទ្យាសាស្ត្រមានអ្វីខ្លះដែលប៉ះពាល់ដល់ជីវិតប្រចាំថ្ងៃរបស់យើង ពីឋាមពលចម្រាញ់ពីធម្មជាតិ ទៅដល់ការផ្លាស់ប្តូរអាកាសធាតុ។
- ទៅទស្សនាសារៈមន្ទីរវិទ្យាសាស្ត្រ ការអប់រំនៅក្រៅ សួនសត្វ និងការការពារធម្មជាតិ ដើម្បីបង្ហាញកូនថា លោកអ្នកឲ្យតម្លៃដល់វិទ្យាសាស្ត្រ។
- កត់សម្គាល់ធម្មជាតិក្នុងលោកជាមួយកូនរបស់លោកអ្នក ដោយ ចង្អុលបង្ហាញអ្វីៗផ្សេងៗ ដូចជា ស្លឹកឈើលាស់ចេញពីដើមនៅ និទាឃរដូវ ឬចិញ្ចើមផ្លូវដែលប្រេះដោយសារការការប្រែប្រួលពីកក ទៅរលាយ និងដោយសារអាកាសធាតុ។

### សង្គមសាស្ត្រ

- ពិភាក្សាពីជំនាញការផ្នែកហិរញ្ញវត្ថុ ដូចជាការលៃលកប្រាក់កាស សរសេរសែក និងសន្សំថវិកា
- ក្នុងផ្ទះសម្បែង អនុវត្តអ្វីៗទាំងនេះក្នុងស្ថានភាពប្រចាំថ្ងៃ
- អានសៀវភៅជុំគ្នា ហើយពិភាក្សាដំណើរហេតុផ្សេងៗអំពីវប្បធម៌ខុសៗគ្នា។
- ពិភាក្សាគ្នាអំពីស្ថានការណ៍ថ្មីៗក្នុងព័ត៌មាន (ទូរទស្សន៍ កាសែត និងទស្សនាវដ្តី)។ ពន្យល់ និងពិភាក្សាគ្នាអំពីសារៈសំខាន់នៃចលនាទាមទារសិទ្ធិមនុស្ស។

### ការសរសេរ

- ឲ្យកូនសរសេរសំបុត្រ ឬអ៊ីមេល ដែលផ្តល់ព័ត៌មានដល់ញាតិសន្តាន ឬមិត្តភក្តិ ពីព្រឹត្តិការណ៍ ថ្មីៗ ពីការកត់សម្គាល់ និងពីមនោសញ្ចេតនា។
- ឲ្យកូនសរសេរវិធីធ្វើអ្វីផ្សេងៗសម្រាប់កិច្ចការប្រចាំថ្ងៃ (ដូចជា របៀបធ្វើនំប័ងដាក់សណ្តែកដីហ្មត់និងចាហួយ- peanut butter and jelly sandwich)។
- ជាញឹកញាប់ សិស្សានុសិស្សព្យាយាមបញ្ចុះបញ្ចូលឲ្យឪពុកម្តាយអនុញ្ញាតឲ្យពួកគេធ្វើ ឬមានអ្វីមួយ។ ឲ្យកូនរបស់លោកអ្នកសរសេររឿងដែលគួរឲ្យជឿ ដកស្រង់នូវហេតុផល និងភស្តុតាងដែលគិតដល់ការបារម្ភ ឬជម្លោះ។
- ចូលរួមក្នុងការសរសេររឿងខ្លីៗ ឬរឿងល្ខោន ជាមួយកូន អំពីការដកពិសោធន៍ផ្ទាល់ខ្លួន។ ចែកឲ្យក្រុមគ្រួសាររបស់លោកអ្នកមើល។

### សុខភាព និងសុខមាលភាព

- ឲ្យកូនញ៉ាំអាហារពេលព្រឹកដែលមានជីវជាតិរៀងរាល់ព្រឹក នៅផ្ទះ ឬនៅសាលា។
- ចូលរួមក្នុងសកម្មភាពដែលបញ្ចេញពលកម្ម កុំមើលទូរទស្សន៍ និងវីឌីអូច្រើនពេក។
- ពិភាក្សាគ្នាពីកំហឹង និងមធ្យោបាយទប់កំហឹង។
- ពិភាក្សាគ្នាពីការសម្លុតធ្វើបាប វិធីជៀសវាងមិនឲ្យមានការសម្លុតធ្វើបាប និងវិធីជួយអ្នកឯទៀតដែលកំពុងជួបប្រទះនឹងការធ្វើបាប។
- ពិភាក្សាគ្នាពីអាកប្បកិរិយាដែលនាំឲ្យមានគ្រោះថ្នាក់ និងមធ្យោបាយជៀសវាងការបង្ខិតបង្ខំពីមិត្តភក្តិ។

### សិល្បៈ និងតន្ត្រី

- ច្រៀង និងលេង បទភ្លេងដែលមានកម្រិតខ្ពស់ បង្ហាញបែបបទតន្ត្រីខុសៗគ្នា និងតាមសម័យកាល។
- ផ្តល់សម្ភារៈសិល្បៈសមរម្យ ដើម្បីរៀន គូរគំនូរ គំនូរលាបពណ៌ បោះពុម្ព និងចម្លាក់។
- ទៅចូលរួមការប្រគំតន្ត្រី និងសារៈមន្ទីរវិចិត្រសិល្បៈ

### ភាសាបរទេស

- ហាត់ពាក្យក្នុងខ្លាចដែលបានរៀនជាមួយកូន។
- លេងល្បែងទាយជាមួយកូន ដោយយកពាក្យដែលបានរៀនមកប្រើ។

#### ស្ថិតនៅក្នុងស្ថានភាពរៀនធ្លាក់

ប្រសិនបើសិស្ស ស្ថិតនៅក្នុងស្ថានភាពរៀនធ្លាក់ នឹងមានកំណត់សម្គាល់នៅខាងក្រោមរបាយការណ៍ពិន្ទុលើកទីពីរ និងទីបី។ របាយការណ៍ពិន្ទុចុងក្រោយបង្អស់នឹងបង្ហាញថាតើគេនឹងតម្លើងថ្នាក់សិស្ស ឬចាត់ឲ្យទៅកម្មវិធីរៀនក្នុងរដូវក្តៅឬអត់។

#### ថ្នាក់ទី៤ - ៧

សិស្សដែលរៀនបានពិន្ទុ D ឬ F ផ្នែកគNiតវិទ្យា ការអាន និងគណិតសាស្ត្រ  គឺស្ថិតនៅក្នុងស្ថានភាពរៀនធ្លាក់។

#### ថ្នាក់ទី៨

សិស្សដែលរៀនបានពិន្ទុ D ឬ F សម្រាប់មុខវិជ្ជាណាមួយនៃមុខវិជ្ជាសំខាន់ទាំងបួន (គណិតវិទ្យា ការអាន វិទ្យាសាស្ត្រ ឬ សង្គមកិច្ច) គឺស្ថិតនៅក្នុងស្ថានភាពរៀនធ្លាក់។

**ក្រសួងអប់រំ**
**នៃ**
**ទីក្រុងហ្វីឡាដែលហ្វ្យ៉ា**